ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ: ៤៩៧ ស.ជណ.ប.ស្ល

# សេចក្តីជូនដំណឹង
## ស្តីពី
## ការហាមឃាត់ការទិញ-លក់ ការដឹកជញ្ជូន ការប្រមូល និងការធ្វើសន្និធិកេសរកូលព្រៃនៅក្នុងតំបន់ការពារធម្មជាតិ

ក្រសួងបរិស្ថាន សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា កន្លងមកមានជនខិលខូចមួយចំនួនបានធ្វើការបំផុសព័ត៌មាននៅក្នុងបណ្តាញសង្គមអំពីការប្រមូលទិញប្រភេទកេសរកូលព្រៃក្នុងតម្លៃខ្ពស់ ដែលជាហេតុជំរុញឱ្យមានការប្រមូលកេសរកូលព្រៃពីតំបន់ការពារធម្មជាតិដោយអនាធិបតេយ្យ។ ទង្វើនេះបានធ្វើឱ្យប៉ះពាល់ដល់ប្រភេទកេសរកូលព្រៃ និងអាចឈានដល់ការផុតពូជទាំងស្រុងនូវប្រភេទកេសរកូលព្រៃមួយចំនួន។ ក្រសួងបរិស្ថានសូមគូសបញ្ជាក់ថា រាល់សកម្មភាពទាំងឡាយដែលបាន និងកំពុងប្រមូលជួញដូរ និងធ្វើអាជីវកម្មប្រភេទកេសរកូលព្រៃពីក្នុងតំបន់ការពារធម្មជាតិទាំងការធ្វើអាជីវកម្ម ឬក្នុងគោលបំណងណាមួយគឺជាសកម្មភាពផ្ទុយនឹងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ មាត្រា ៥៩ ចំណុច០៣ ចំណុច០៤ និងមាត្រា ៦១ ចំណុច០៤។

ក្នុងន័យនេះ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងសិទ្ធិប្រើប្រាស់ធនធានធម្មជាតិរបស់ប្រជាសហគមន៍ស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ក្រសួងបរិស្ថាន សូមដាក់ចេញនូវវិធានការ និងការណែនាំដូចខាងក្រោម៖

- បញ្ឈប់នូវរាល់សកម្មភាពខុសច្បាប់ជាអាទិ៍ ការដឹកជញ្ជូន ការប្រមូល ការធ្វើសន្និធិកេសរកូលព្រៃ
- បញ្ឈប់នូវរាល់សកម្មភាពទិញ-លក់កេសរកូលព្រៃ

ក្រសួងបរិស្ថាន ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងចាត់វិធានការយ៉ាងម៉ឺងម៉ាត់បំផុត ដើម្បីទប់ស្កាត់ និងបង្ក្រាបរាល់សកម្មភាពល្មើសដូចបានរៀបរាប់ខាងលើ ដោយផ្អែកលើនីតិវិធីច្បាប់ជាធរមាន។

ទទួលបានសេចក្តីជូនដំណឹងនេះ សូមក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ជួយធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងនេះឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋដើម្បីបង្កើនការយល់ដឹង និងចូលរួមគោរពច្បាប់ទាំងអស់គ្នា ដោយមិនប្រព្រឹត្តសកម្មភាពគ្រប់រូបភាពនៅក្នុងតំបន់ការពារធម្មជាតិហើយសូមផ្តល់កិច្ចសហការក្នុងការអនុវត្តវិធានការចាំបាច់នានាដោយស្មារតីទទួលខុសត្រូវខ្ពស់ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

ថ្ងៃសុក្រ ៥រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០២០

ក្រសួងបរិស្ថាន

អគារមរតកតេជោ ដីឡូលេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 235 004 / 023 235 006